# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**
**អគ្គនាយកដ្ឋានកសិកម្ម**

លេខ...៥៧៣.........អ.ន.ក

ថ្ងៃ...អង្គារ...២កើត...ខែជេស្ឋ...ឆ្នាំកុរ ឯកស័ក...ព.ស.២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី...០៤...ខែ...មិថុនា...ឆ្នាំ២០១៩

**<u>សូមគោរពជូន</u>**

**ឯកឧត្តមរដ្ឋមន្ត្រី ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**<u>កម្មវត្ថុ</u>** : របាយការណ៍ប្រចាំខែឧសភាស្ដីពី ល្បឿនការងារបង្កបង្កើនផលកសិកម្មរដូវវស្សាឆ្នាំ២០១៩ " គិតត្រឹមថ្ងៃពុធ ១១រោច ខែពិសាខ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣ ត្រូវនឹងថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០១៩ " ។

**<u>ជូនភ្ជាប់</u>** : របាយការណ៍លម្អិតប្រចាំខែឧសភាស្ដីពី ល្បឿនការងារបង្កបង្កើនផលកសិកម្មរដូវវស្សាឆ្នាំ២០១៩ "គិតត្រឹមថ្ងៃពុធ ១១រោច ខែពិសាខ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣ ត្រូវនឹងថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០១៩"
ចំនួន ..........................................................................................................០១ច្បាប់ ។

សេចក្ដីដូចមានចែងក្នុងកម្មវត្ថុ និងជូនភ្ជាប់ខាងលើ ខ្ញុំបាទសូមគោរពជម្រាបជូន **ឯកឧត្តមរដ្ឋមន្ត្រី** មេត្តាជ្រាបថា ល្បឿនការងារបង្កបង្កើនផលកសិកម្មរដូវវស្សាឆ្នាំ២០១៩ " គិតត្រឹមថ្ងៃពុធ ១១រោច ខែពិសាខ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣ ត្រូវនឹងថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០១៩ " សម្រេចបាន:

| | | | | | |
|---|---|---|---|---|---|
| ក. ដំណាំស្រូវ | : ស្ទូង និងព្រោះអនុវត្តបានចំនួន ៤៨៤ ០០៧ ហ.ត ស្មើនឹង ១៨,៧២ % | | | | |
| | នៃផែនការចំនួន ២ ៥៨៦ ១៥២ ហ.ត | | យឺតជាងឆ្នាំមុន | ៣៥០ ៨៨៣ ហ.ត | |
| ខ. ដំណាំរួមផ្សំ | : អនុវត្តបាន | ១៤ ១០២ ហ.ត | យឺតជាងឆ្នាំមុន | ១១ ៨១៩ ហ.ត | |
| គ. ដំណាំឧស្សាហកម្ម | : អនុវត្តបាន | ២៥៨ ៤៣៩ ហ.ត | យឺតជាងឆ្នាំមុន | ១៥៦ ៦៣៤ ហ.ត | |

អាស្រ័យដូចបានគោរពជម្រាបជូនខាងលើសូម **ឯកឧត្តមរដ្ឋមន្ត្រី** មេត្តាជ្រាបជាសេចក្ដីរាយការណ៍ ដោយក្ដីអនុគ្រោះ។

សូម **ឯកឧត្តមរដ្ឋមន្ត្រី** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំបាទ។

**ប្រតិភូរាជរដ្ឋាភិបាលកម្ពុជាទទួលបន្ទុកជាអគ្គនាយក**
**នៃអគ្គនាយកដ្ឋានកសិកម្ម**

អគ្គនាយករង

**ស្រ៊ុន សុខុម**

**<u>ចំលងជូន</u> ៖**
- ឯកឧត្តមរដ្ឋលេខាធិការទទួលបន្ទុកអគ្គនាយកដ្ឋានកសិកម្ម
- ឯកឧត្តម លោកជំទាវ អនុរដ្ឋលេខាធិការទទួលបន្ទុកអគ្គនាយកដ្ឋានកសិកម្ម
- ឯកឧត្តមអគ្គលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
  "ដើម្បីគោរពជូនជ្រាប"
- នាយកដ្ឋានកិច្ចការរដ្ឋបាល
- នាយកដ្ឋានផែនការ និងស្ថិតិ
- នាយកដ្ឋានពាក់ព័ន្ធរបស់អគ្គនាយកដ្ឋានកសិកម្ម
- ឯកសារ កាលប្បវត្តិ

អាសយដ្ឋានលេខ: ៥៤បេ/៤៩អេហ្វ ផ្លូវលេខ ៣៩៥-៦៥៦ សង្កាត់ទឹកល្អក់៣ ខណ្ឌទួលគោក រាជធានីភ្នំពេញ ទូរស័ព្ទលេខ:(០២៣) ៨៨៣ ៤២៧ ទូរសារលេខ:(០២៣) ៨៨៣ ៤២៧
Address # 54B/49F, Street 395-656, Sangkat Toeuk Laak 3, Khan Tuol Kok, Phnom Penh. Cambodia, Phone : (023) 883 427, Fax : (023) 883 427